# Before you Sign

## ប្ដីប្រពន្ធរស់នៅផ្សេងគ្នាឬក៏ការលែងលះដាច់

សូមស្វាគមន៍ចូលទៅក្នុងការមុននឹងអ្នកចសូមស្វាគមន៍ចូលទៅក្នុងការមុននឹងអ្នកចុះហត្ថលេខាPodcast (ប្រព័ន្ធផ្សាយដំណឹងក្នុងអ៊ីនធឺណិត).

ប្រព័ន្ធផ្សាយដំណឹងតាមរយៈអ៊ីនធឺណិតនេះបានធ្វើឡើងដើម្បីជួយលោកអ្នកឱ្យបានយល់ប្រសើរជាងមុនអំពីច្បាប់និងសិទ្ធិរបស់ខ្លួននៅក្នុងរដ្ឋអង់តារីយ៉ូ។

ប្រសិនបើលោកអ្នកយល់ពីសិទ្ធិនិងការទទួលខុសត្រូវរបស់ខ្លួន លោកអ្នកនឹងអាចជ្រើសរើសនូវអ្វីៗដែលអ្នកដឹងថាល្អហើយត្រឹមត្រូវសម្រាប់ការរស់នៅរបស់លោកអ្នកនៅក្នុងប្រទេសកាណាដា។

សំខាន់ខ្លាំងណាស់លោកអ្នកត្រូវដឹងថាព័ត៍មានដែលផ្សាយចេញតាមប្រព័ន្ធអ៊ីនធឺណិតនេះគឺមិនមែនជាដំបូន្មានច្បាប់អជ្ញាដើម្បីជួយដោះស្រាយស្ថានការណ៍របស់លោកអ្នកនោះទេ។ ដំណឹងទាំងនេះគ្រាន់តែជាដំណឹងអំពីច្បាប់អជ្ញាខ្លះៗតែប៉ុណ្ណោះដែលជួយលោកអ្នកឲ្យបានយល់ខ្លះៗដែលលោកអ្នកកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ន។

ថ្ងៃនេះយើងនឹងពិពណ៌នាអំពីប្ដីប្រពន្ធរស់នៅផ្សេងគ្នាឬការលេងលះគ្នាដាច់នៅក្នុងរដ្ឋអង់តារីយ៉ូ(Ontario). តើលោកអ្នកកំពុងពិចារណារឿងរស់នៅផ្សេងពីគ្នារវាងប្ដីប្រពន្ធឬក៏លែងលះគ្នាដាច់ឬ? បើពិតមែន នោះមានជំហានសំខាន់ៗ ដែលទាក់ទងទៅក្នុងករណីទាំងនេះ។

ជំហានទីមួយដើម្បីទទួលការលែងលះគ្នាដាច់ គឺត្រូវតែមានការរស់នៅផ្សេងពីគ្នាជាមុនសិន។ ការរស់នៅផ្សេងគ្នាគឺបញ្ជាក់ប្រាប់ថាលោកអ្នកចង់បញ្ចប់ទំនាក់ទំនងរវាងប្ដីប្រពន្ធជារៀងរហូត។ ប្ដីឬក៏ប្រពន្ធត្រូវធ្វើការសំរេចចិត្តរួមគ្នាថាពេលណាអ្នកទាំងពីរបានរស់នៅផ្សេងគ្នា។ ថ្ងៃខែដែលរស់នៅផ្សេងពីគ្នានោះសំខាន់។ ថ្ងៃខែដែលអ្នកចាប់ផ្ដើមរស់នៅផ្សេងពីគ្នា ដែលមានឧទាហរណ៍យ៉ាងដូច្នេះ គឺលោកអ្នកឈប់រួមដំណេក នៅក្នុងបន្ទប់តែមួយជាមួយគ្នា។ លោកអ្នកបរិភោគបាយទឹកផ្សេងពីគ្នា។ ពេលទំនេរវិស្សមកាលម្ដងៗគឺមិនទៅជាមួយគ្នា។ កាលបានសម្រេចរួចហើយអំពីថ្ងៃខែលោកអ្នកអាចសរសេរជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រមទៅវិញទៅមកថានិងដោះស្រាយដូចម្ដេចចំពោះរឿងរ៉ាវទាំងអស់នៅពេលការលែងលះ នោះមកដល់។ លោកអ្នកអាចរកបានក្រដាសស្នាមបទសំណុំអំពីការលែងលះ នៅក្នុងទំព័របណ្ដាញជំហានទៅក្នុងយុត្តិធម៌(stepstojustice.ca website)

សំណូមពររបស់លោកអ្នកដើម្បីឲ្យបានទទួលការលេងលះគ្នានោះមិនអាចអនុញ្ញាតបានទេទាល់តែលោកអ្នកបានរស់នៅបែកគ្នាក្នុងរយៈពេលមួយឆ្នាំយ៉ាងខ្លីបំផុត។

ការរស់នៅផ្សេងពីគ្នារវាងប្ដីប្រពន្ធគឺជាមូលដ្ឋានសម្រាប់ការលែងលះ តែក្នុងករណីនេះក៏អាចទៅរួចដែរ

គឺអាចទទួលការអនុញ្ញាតបានឆាប់មុនមួយឆ្នាំប្រសិនបើជាករណីដែលលោកអ្នកដាក់ចូលទៅក្នុងសំណូមពរដោយមានការផិតក្បត់ ឬក៏ការធ្វើបាបផ្លូវកាយឬផ្លូវចិត្ត។

ដើម្បីបញ្ជាក់ពីការរស់នៅបែកគ្នាមិនបាច់រស់នៅផ្ទះផ្សេងគ្នានោះទេ។

ក្នុងខណៈដែលលោកអ្នកទាំងគូរបានសម្រេចពីរឿងការរស់នៅផ្សេងគ្នានិងការលែងលះគ្នារួចហើយ នោះលោកអ្នកត្រូវគិតពីរឿងសំខាន់ៗដែលមាននៅក្នុងការលែងលះគ្នានេះ

ដូចជាការសម្រេចចិត្តនិងការជ្រើសរើស។ ឧទាហរណ៍ដូចជា តើនរណាអាចបន្តរស់នៅក្នុងផ្ទះនៃគ្រួសារបច្ចុប្បន្ន? បើមានកូនតើកូននឹងនៅជាមួយអ្នកណាប្ដីឬក៏ប្រពន្ធ?

តើអ្នកណានិងចិញ្ចឹមបីបាច់ថែរក្សាកូនហើយនៅផ្ទះអ្នកណា? តើអ្នកណាជាអ្នកសម្រេចក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន? តើអ្នកណានិងទំនុកបម្រុងផ្នែកប្រាក់ចំណូលជួយដល់គូពីមុនរបស់ខ្លួននិងកូនៗ។

តើនិងបែងចែកយ៉ាងដូចម្ដេចនូវអ្វីៗដែលជាទ្រព្យសម្បត្តិរួមពីមុន។ បើលោកអ្នកមិនមែនជាសញ្ជាតិកាណាដាទេត្រូវគិតពីរឿងអន្តោប្រវេសន៍របស់លោកអ្នកដែលនឹងត្រូវផលប៉ះពាល់។ នៅក្នុងករណីខ្លះគូពីមុនរបស់លោកអ្នកអាចនិងនិយាយ ថា គាត់ នឹងត្រូវឲ្យអាជ្ញាធរ និរទេសអ្នកចេញពីកាណាដាបើលោកអ្នកចង់រស់នៅបែកបាក់គ្នាឬលែងលះគ្នាដាច់ស្រេចជាមួយនឹងគាត់។ និរទេសបានន័យថាលោកអ្នកត្រូវបានបង្ខំឲ្យចាកចេញពីប្រទេសណាមួយ។ គគូរបស់លោកអ្នកពីមុនមិនអាចនិរទេសលោកអ្នកបាននោះទេ។

គឺមានតែរដ្ឋាភិបាលកាណាដាទាំងមូលដែលមានអំណាចដើម្បីនិរទេសលោកអ្នក។ ចូរលោកអ្នកពិភាក្សា ជាមួយនិងអ្នកជំនាញច្បាប់ ប្រសិនជាលោកអ្នកមិនមែនជាសញ្ជាតិកាណាដា

# Before you Sign

ដើម្បីអោយលោកអ្នកបានទទួលព័ត៏មានដែលត្រូវ ដែលទាក់ទងចំៗនិងស្ថានការណ៍របស់លោកអ្នក។
វាគឺជាការសំខាន់ដែលលោកអ្នកដឹងថាការលែងលះនិងការរស់នៅផ្សេងគ្នានិងឬមិនមានផលប៉ះពាល់ទៅលើការសុំជ្រកកោនរបស់លោកអ្នក។

ជាការសំខាន់មួយដើម្បីលោកអ្នកយល់ឱ្យបានច្បាស់ថា មានការខុសគ្នា ក្នុងករណីអ្នកដែលមាន វិញ្ញាបនបត្ររៀបការនិងអ្នកដែលគ្រាន់តែរស់នៅជាមួយគ្នា។ ឧទាហរណ៍ដូចជារឿង
សុំឲ្យមានការបែងចែកទ្រព្យសម្បត្តិដែលនៅសល់ពីការជំពាក់គេស្មើគ្នាបើលោកអ្នកមានវិញ្ញាបនបត្ររៀបការក៏ប៉ុន្តែបើលោកអ្នកមិនមានវិញ្ញាបនបត្ររៀបការ
គ្រាន់តែជាអ្នករស់នៅជាមួយគ្នាប៉ុណ្ណោះមិនអាចនិងមានសំណូមពរដូច្នេះបានឡើយ។ គូដែលគ្រាន់តែរស់នៅជាមួយគ្នា គ្មានសិទ្ធិក្នុងការបែងចែកទ្រព្យសម្បត្តិនោះទេ
តែអាចបែងចែកបានលុះត្រាតែលោកអ្នកមានឈ្មោះទាំងពីរនាក់នៅលើទំនិញណាមួយដែលអ្នកបានចំណាយប្រាក់រួមគ្នា។
អ្នកដែលបានរៀបការនិងអ្នកដែលមិនបានរៀបការអាចមានសំណូមពរដើម្បីឱ្យម្នាក់ដែលមានសមត្ថភាពជួយដល់អ្នកដែលខ្វះខាតនៅពេលបែកបាក់គ្នា។

ដើម្បីឱ្យការលេងលះបានសម្រេចពិតប្រាកដលោកអ្នកត្រូវតែដាក់សំណូមពរចូលទៅក្នុងសាលាកាត់ក្តី សំណូមពរសុំការលែងលះគ្នា ត្រូវដាក់ចូលទៅក្នុងសាលាចៅក្រមយុត្តិធម៏ជាន់ខ្ពស់
ឬសាខាសាលាចៅក្រមផ្នែកគ្រួសារនៃ សាលាជាន់ខ្ពស់ចៅក្រមយុត្តិធម៏។ ម្នាក់នៅក្នុងចំណោមអ្នកទាំងពីរអាចដាក់សំណុំរឿងចូលទៅក្នុងការសុំលែងលះបាន។ ការដាក់សុំលែងលះ
ប្រសិនបើជាលោកអ្នកចង់ដាក់ទាំងពីរនាក់ក៏បានដែរ។ យន្តការនៃការលែងលះ អាចមានដំណើរការបាននៅក្នុងក្រុងដែលលោកអ្នកកំពុងតែរស់នៅ។

ថ្លៃសេវាកម្មដែលលោកអ្នកត្រូវចំណាយដើម្បីអោយលោកអ្នកបានទទួលការលែងលះនៅ រដ្ឋអង់តារីយ៉ូ។ ការបង់ថ្លៃដំបូងគឺត្រូវបង់នៅពេលដែលដាក់សំណូមពរដើម្បីសុំការលែងលះ។
ហើយមានការបង់ថ្លៃជាបន្តបន្ទាប់នៅពេលដែលចៅក្រមកំពុងពិនិត្យពិច័យនូវសំណូមពរទាំងនោះ។ ជាការសំខាន់មួយដើម្បីឲ្យលោកអ្នកបានជ្រាប
ថាថ្លៃសេវាកម្មទាំងនេះគឺលោកអ្នកបង់ចំពោះការចំណាយពេលពិនិត្យពិច្ច័យសំណុំរឿងនិងក្រដាសស្នាមតែប៉ុណ្ណោះ។ ប្រសិនបើលោកអ្នកត្រូវការការគាំទ្រពីសំណាក់អ្នកច្បាប់
នោះលោកអ្នកនិងបង់ថ្លៃខ្ពស់ដើម្បីឲ្យបានទទួលការលែងលះគ្នា។

យើងសង្ឃឹមថាលោកអ្នករកបាន ក្នុងប្រព័ន្ធផ្សាយដំណឹងតាមអ៊ីនធឺណិតនេះហៅថាផដ់ខាស្ត(Podcast) នូវព័ត៏មានសំខាន់ផ្នែកច្បាប់ អំពីការរស់នៅបែកគ្នារវាងប្តីប្រពន្ធនិងការលែងលះគ្នាដាច់ស្រេច
នៅក្នុង រដ្ឋអង់តារីយ៉ូ។ ប្រសិនបើលោកអ្នកមានចម្ងល់អ្វីអំពីរឿងការថែរក្សាកូនៗនិងការចូលទៅនៅក្បែរខ្លួនកូនបន្ទាប់ពីការដែលរស់នៅដាច់ឡែកពីគ្នាឬក៏ការលែងលះគ្នាដាច់ស្រេច
នោះសូមចំណាយពេលវេលាដើម្បីស្តាប់ព័ត៏មានផ្នែកច្បាប់នៅក្នុងរឿងរ៉ាវនេះ។

ប្រសិនបើលោកអ្នកនៅមានសំណួរអំពីរពីរឿងទាំងអស់នេះ សូមមេត្តាគិតដើម្បីត្រឡប់មកសួរតាមតាមរយៈភ្នាក់ងារបម្រើសេវាកម្ម ហើយនិងអ្នកដែលប្រាប់លោកអ្នកអំពីព័ត៏មានតាមអ៊ីនធឺណិតនេះ។

បើសិនជាលោកអ្នកមានម៉ាស៊ីនគិតស្វ័យប្រវត្តិ(កុំព្យូទ័រ)អាចចូលទៅក្នុងទំព័រអ៊ីនធឺណិតឈ្មោះជំហានចូលទៅក្នុងយុត្តិធម៏ (stepstojustice.ca)
ឬអង្គការអន្តោប្រវេសន៍(settlement.org)ដើម្បីទទួលព័ត៏មានបន្ថែម។ ប្រសិនបើជាលោកអ្នកបានដឹងថាខ្លួនត្រូវការដំបូន្មានដែលត្រឹមត្រូវតាមច្បាប់, ការគាំទ្រ,
ឬអ្នកច្បាប់សម្រាប់ជាតំណាងរបស់លោកអ្នក, សូមទាក់ទងមកភ្នាក់ងារជំនួយផ្នែកច្បាប់រដ្ឋអង់តារីយ៉ោ(Legal Aid Ontario) ១-៨០០-៦៦៨-៨២៥៨ ពីថ្ងៃច័ន្ទទល់ថ្ងៃសុក្រ ពីម៉ោង 8ព្រឹកដល់ម៉ោង
5ល្ងាច (EST) ដែលមានជាភាសាផ្សេងៗគ្នាចំនួន 300 ភាសា។ ព័ត៏មានដែលចេញផ្សាយតាមប្រព័ន្ធអ៊ីនធឺណិតនេះបានទទួលឧបត្ថម្ភជាប្រាក់ដោយភ្នាក់ងារបម្រើឈ្មោះគ្រឹះស្ថានច្បាប់ (LAW
FOUNDATION)(YWCA-ST THOMAS) សហគមន៍យុវតីគ្រឹស្ទានទីក្រុងសាំងតូម៉ាស់ទទួលខុសត្រូវនៅក្នុងព័ត៏មាននេះដែលសរសេរជាលាយលក្ខណ៍អក្សរចេញផ្សាយ។